## លទ្ធភាពទទួលយកព័ត៌មានរបស់លោកអ្នក..

លោកអ្នកមានសិទ្ធិទទួលយកព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានផ្នែកសុខភាពរបស់លោកអ្នក ឬប្រសិនបើលោកអ្នកប្រាថ្នានឹងធ្វើដូច្នោះ សូមទាក់ទងជាមួយអ្នកសំរបសំរួលគិលានដ្ឋានរោគតំណពូជដែលលោកអ្នកអញ្ជើញទៅ ឬផ្ញើតាមអ៊ីម៉េល mail@genetichealthvic.net.au។

បុគ្គលិក **Genetic Health** ដែលទាក់ទិនក្នុងរឿងមើលថែរបស់លោកអ្នក គឺជាអ្នកផ្តល់ធនធានផ្នែកព័ត៌មានយ៉ាងច្រើន ហេតុដូច្នេះយើងសូមណែនាំលោកអ្នកឲ្យនិយាយទៅកាន់សមាជិកបុគ្គលិកណាម្នាក់ ប្រសិនបើលោកអ្នកមានចម្ងល់ណាមួយ។

យើងមានទំរង់ការប្តឹងតវ៉ាជាផ្លូវការ ដើម្បីដោះស្រាយលើកង្វល់ណាមួយដែលលោកអ្នកអាចមានអំពីការមើលថែរបស់លោកអ្នក។ ប្រសិនបើលោកអ្នកសំគាល់ឃើញព័ត៌មាននៅក្នុងសំណុំឯកសាររោគតំណពូជរបស់លោកអ្នកដែលលោកអ្នកមិនយល់ស្រប ឬមិនត្រឹមត្រូវ នោះលោកអ្នកមានសិទ្ធិស្នើសុំឲ្យគេកែប្រែសំណុំឯកសារនោះ។

នៅក្នុងករណីខ្លះទៀត មានសមាជិកមួយចំនួនមកពីគ្រួសារដដែល គេត្រូវការស្វែងរកការធ្វើរោគវិនិច្ឆ័យ និងឱវាទណែនាំខាងរោគតំណពូជពី Genetic Health។ លោកអ្នកមានសិទ្ធិទទួលយកព័ត៌មានផ្ទាល់ខ្លួន និងផ្នែកសុខភាពរបស់លោកអ្នក។ ទោះជាយ៉ាងណាក្តី លោកអ្នកមិនបានគេអនុញ្ញាតឲ្យពិនិត្យមើលសំណុំឯកសាររោគតំណពូជទាំងស្រុងឡើយ ដោយព្រោះថាសំណុំឯកសារនោះអាចមានចុះនូវព័ត៌មានអំពីសមាជិកគ្រួសារឯទៀត ហើយយើងប្តូរផ្តាច់ថានឹងការពារព័ត៌មានរបស់គេ ក៏ដូចជាព័ត៌មានរបស់លោកអ្នកដែរ។

## ព័ត៌មានច្រើនថែមទៀត..

សូមទូរស័ព្ទលេខ 03 8341 6201 ឬបើកមើលវិបសាយ
www.genetichealthvic.net.au

**ការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរគួរបញ្ជូនទៅ:**

Clinical Quality Liaison Officer
Genetic Health Services Victoria
Murdoch Childrens Research Institute
Flemington Road Parkville
Victoria 3052 Australia



ភាពឯកជនរបស់លោកអ្នក
- គោលការណ៍សុខភាពខាងរោគតំណពូជ

GENETICHEALTH | VCGSPATHOLOGY
Victorian Clinical Genetics Services



# ភាពឯកជនរបស់លោកអ្នក



## គោលការណ៍សុខភាពខាងរោគតំណពូជ

Your Privacy
Genetic Health Policy
**Khmer**

GENETICHEALTH | VCGSPATHOLOGY
Victorian Clinical Genetics Services



## ការពារភាពឯកជនរបស់លោកអ្នក..

**Genetic Health Services** (កិច្ចបំរើសុខភាពផ្នែករោគតំណពូជ) មានគោលការណ៍តឹងរ៉ឹងដើម្បីការពារភាពឯកជននៃព័ត៌មានផ្ទាល់ខ្លួន និងផ្នែកសុខភាពរបស់លោកអ្នក។ ព័ត៌មានរបស់លោកអ្នកត្រូវគេរក្សាទុកយ៉ាងសន្តិសុខនៅក្នុងសំណុំឯកសាររោគតំណពូជមួយ ដែលដាច់ដោយឡែកពីកំណត់ត្រារបស់មន្ទីរពេទ្យ ហើយមានតែអ្នកវិជ្ជាជីវៈទាក់ទិននៅក្នុងការមើលថែរបស់លោកអ្នកប៉ុណ្ណោះ ដែលគេមានលទ្ធភាពប្រើប្រាស់សំណុំរឿងរបស់លោកអ្នក។

ព័ត៌មានផ្នែករោគតំណពូជរបស់លោកអ្នកអាចមានការទាក់ទិនដល់សមាជិកគ្រួសារ។ ញាតិសន្តានមានសិទ្ធិស្វែងរកព័ត៌មានអំពីលក្ខណៈរោគដែលអាចប៉ះពាល់ដល់គេ។ ដើម្បីការពារភាពឯកជន និងភាពសម្ងាត់ ការអនុញ្ញាតរបស់លោកអ្នកនឹងត្រូវគេស្វែងរក មុននឹងគេបញ្ចេញប្រាប់នូវព័ត៌មានរបស់លោកអ្នក។



## តើព័ត៌មានណាខ្លះត្រូវគេប្រមូលយក..

នេះគឺជាការចាំបាច់ដែលយើងត្រូវប្រមូលយកព័ត៌មានអំពីលោកអ្នក និងប្រវត្តិរបស់លោកអ្នក មានរួមទាំងប្រវត្តិពហុតំណពូជណាមួយ។ យើងក៏ត្រូវការធ្វើកំណត់ត្រាផងដែរអំពីឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នក ឈ្មោះវេជ្ជបណ្ឌិតក្នុងតំបន់របស់លោកអ្នក និងគ្រូពេទ្យឯទៀត ឬអ្នកវិជ្ជាជីវៈផ្នែកសុខភាពដែលទាក់ទិនក្នុងការមើលថែលោកអ្នក។

ព័ត៌មានផ្នែកសុខភាពផ្ទាល់ខ្លួនរបស់លោកអ្នកនឹងត្រូវគេធ្វើកំណត់ត្រាយ៉ាងត្រឹមត្រូវដែលអាចធ្វើទៅបាន ហើយនឹងត្រូវគេរក្សាទុកដោយសន្តិសុខជាដដែល។ សូមទាក់ទងជាមួយយើង ប្រសិនបើព័ត៌មានលំអិតទាំងឡាយដូចជាអាសយដ្ឋានរបស់លោកអ្នក ឬវេជ្ជបណ្ឌិតក្នុងតំបន់មានការផ្លាស់ប្តូរ។



ធ្វើការនៅក្រោមគោលការណ៍
នៃធម្មនុញ្ញរដ្ឋវិចតូរីយ៉ា
ហើយនិងសិទ្ធិមនុស្ស
និងការទទួលខុសត្រូវ
ដើម្បីការពារសិទ្ធិទាំងឡាយ
របស់លោកអ្នក។



## របៀបដែលព័ត៌មានរបស់លោកអ្នកត្រូវបានគេយកប្រើ និងបញ្ចេញឲ្យគេដឹង..

**Genetic Health** នឹងផ្តល់នូវសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរអំពីការពិគ្រោះ បន្ទាប់ពីការណាត់ជួបរបស់លោកអ្នក។ យើងផ្តល់ព័ត៌មាននេះទៅលោកអ្នក វេជ្ជបណ្ឌិតក្នុងតំបន់របស់លោកអ្នក និងវេជ្ជបណ្ឌិតដែលបញ្ជូនលោកអ្នក និងអ្នកវិជ្ជាជីវៈឯទៀតណាម្នាក់ ឬបុគ្គលណាម្នាក់ដែលលោកអ្នកជ្រើសតាំង។ តាមធម្មតាការនេះធ្វើឡើងដោយផ្ញើតាមប៉ុស្តិ៍ ទូរសារ ឬការផ្ញើតាមបែបអេឡិកត្រូនិក។ លោកអ្នកក៏អាចជ្រើសតាំងផងដែរ អំពីនរណាដែលមិនគួរទទួលច្បាប់ចម្លងនៃលិខិតនេះ។

វេជ្ជបណ្ឌិតក្នុងតំបន់របស់លោកអ្នក ឬវេជ្ជបណ្ឌិតដែលបញ្ជូនលោកអ្នកអាចទាក់ទងជាមួយយើងដើម្បីទទួលយកព័ត៌មានបន្ថែម។ ប្រសិនបើព័ត៌មានតម្រូវដោយបុគ្គលណាម្នាក់ដែលលោកអ្នកមិនបានជ្រើសតាំង នោះយើងនឹងស្វែងរកការអនុញ្ញាតយល់ព្រមជាមុនពីលោកអ្នក។

យូរៗម្តង សំណុំឯកសារផ្នែករោគតំណពូជរបស់លោកអ្នកអាចត្រូវបើកមើលដោយបុគ្គលិក Genetic Health ដើម្បីឆែកពិនិត្យមើលសំរាប់ការហាត់មើលការធានាលើគុណភាព ឬពេលណាលក្ខណៈរោគជាក់លាក់របស់លោកអ្នកអាចជួយយើងរៀបគ្រោងការមើលថែផ្នែកសុខភាពសំរាប់អ្នកឯទៀត ដែលបានប៉ះពាល់ដោយលក្ខណៈរោគដូចគ្នា។ ព័ត៌មានក៏អាចត្រូវគេបញ្ជូនទៅក្រសួងកិច្ចបំរើប្រជាជនដែរ ក៏ប៉ុន្តែគេនឹងមិនសំគាល់ដឹងអំពីរូបលោកអ្នកឡើយ។

ការស្រាវជ្រាវណាមួយដែលចាត់ចែងឡើងដោយបុគ្គលិករបស់យើងនឹងត្រូវធ្វើឡើងដោយអនុលោមទៅតាមគោលការណ៍របស់ទីប្រឹក្សាជាតិលើការស្រាវជ្រាវផ្នែកសុខភាព និងវេជ្ជសាស្ត្រ និងគោលការណ៍ដែលទាក់ទិនឯទៀត ដើម្បីឲ្យច្បាស់ប្រាកដថាបានប្រកាន់ខ្ជាប់តឹងរ៉ឹងលើច្បាប់ភាពសម្ងាត់ផ្ទាល់ខ្លួន និងភាពឯកជន។

**Genetic Health** អាចតម្រូវដោយច្បាប់ដើម្បីបញ្ចេញនូវព័ត៌មានផ្នែកសុខភាព ពេលណាសំណុំឯកសាររោគតំណពូជត្រូវបានទទួលដីការនៅតុលាការ។ លោកអ្នកនឹងបានទទួលដំណឹង ប្រសិនបើហេតុការណ៍នេះកើតមានឡើង។